# មជ្ឈមណ្ឌលឯកសារកម្ពុជា

**បាឋកថាស្តីអំពី**

**«កេរដំណែលឯកសារ ការចងចាំ និង សំណាងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»**

ដោយ បណ្ឌិត រ៉ែចល ហ៊ូច

**ថ្ងៃព្រហស្បត្តិ៍ ទី១២ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង ៤:០០ រសៀល**

ទីតាំង: វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

អគារ H វិទ្យាស្ថានជាតិអប់រំ

ភាសា: អង់គ្លេស (បកប្រែជាភាសាខ្មែរ)

វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សូមជូនដំណឹងថា វិចិត្រសាលនឹងរៀបចំបាឋកថាទីម្ភៃ ស្តីអំពី **«កេរដំណែលឯកសារ ការចងចាំ និង សំណាងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»** ដោយ បណ្ឌិត រ៉ែចល ហ៊ូច។ សិស្ស និស្សិត គរុសិស្ស និងសាធារណជន អាចចូលរួមកម្មវិធីនេះដោយសេរី។

បទបង្ហាញនេះផ្តល់នូវគំនិតបឋមស្តីអំពីកេរដំណែលឯកសារ ការចងចាំ និងសំណាងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ គំនិតទាំងអស់នេះលេចរូបរាងឡើងនៅក្នុងបទដ្ឋាននៃគម្រោងស្រាវជ្រាវមួយដែលមានគោលដៅស្វែងយល់អំពីទំនាក់ទំនងនៃកេរដំណែលនៃតុលាការខ្មែរក្រហមជាមួយការផ្លាស់ប្តូរជារួមនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាពាក្យថា កេរដំណែល មានអត្ថន័យនិងមានការអនុវត្តយ៉ាងចម្រូងចម្រាសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយ៉ាងណាក៏ដោយ គម្រោងបញ្ចប់របស់តុលាការបច្ចុប្បន្ន ក៏ដូចជាការផ្សំគ្នានៃគម្រោងសំណាងក្នុងក្របខ័ណ្ឌរបស់តុលាការនិងគម្រោងសំណាងក្រៅប្រព័ន្ធតុលាការ តម្រូវឱ្យមានការសិក្សាបន្ថែមទៀតជាចាំបាច់។

បណ្ឌិត រ៉ែចល ហ៊ូច គឺជាភូមិវិទូម្នាក់ដែលមានចំណាប់អារម្មណ៍សិក្សាអំពីច្បាប់ ភូគព្ភនយោបាយ ការចងចាំរួម វប្បធម៌ទស្សនីយភាពរូបភាព និងវត្ថុវប្បធម៌ផ្សេងៗ។ និក្ខេបបទបណ្ឌិតរបស់ រ៉ែចល ហ៊ូច គឺជាការសិក្សាស៊ីជម្រៅទៅលើនយោបាយនៃទីកន្លែងដែលរក្សាការចងចាំពីអតីតកាលក្រោយឆ្នាំ១៩៧៩ រួមទាំងសកម្មភាពទេសចរណ៍និងពិព័រណ៍ផ្សេងៗ។ រ៉ែចល ហ៊ូច បង្រៀននិងធ្វើការស្រាវជ្រាវនៅសកលវិទ្យាល័យមែលប៊ើន តាំងពីឆ្នាំ ២០០៣ ហើយនៅឆ្នាំ២០១៦នេះ រ៉ែចល បានទទួលអាហារូបករណ៍ Australian Research Council Discovery Early Career Researcher Award ដើម្បីធ្វើការស្រាវជ្រាវ។ រ៉ែចល ហ៊ូច គឺជាអ្នកនិពន្ធអត្ថបទសៀវភៅ និង អត្ថបទទស្ស-នាវដ្តីសិក្សាអំពី នយោបាយនៃការចងចាំជាសាធារណៈអំពីរបបខ្មែរក្រហម។ ថ្មីៗនេះ រ៉ែចល បានបោះពុម្ពអត្ថបទមួយចំនួនដែលពិភាក្សាអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសារព័ត៌មានអន្តរជាតិ និង អត្ថបទដែលនិយាយអំពីការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការតុលាការ។


**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

ការចងចាំ និងយុត្តិធម៌

«...សង្គមមួយមិនអាចស្គាល់ខ្លួនឯងបាន ប្រសិនបើសង្គមនោះមិនមានការចងចាំដ៏ត្រឹមត្រូវអំពីប្រវត្តិសាស្រ្តរបស់ខ្លួន។»

ម៉ែន ពិចិត្រ

វិចិត្រសាលសិល្បៈសហសម័យ

មជ្ឈមណ្ឌលឯកសារកម្ពុជា

ទូរសព្ទ +៨៥៥ ២៣ ២១៤ ០០៩

អ៊ីម៉ែល truthmpechet@dccam.org

គេហទំព័រ www.dccam.org